# កុំភ្លេច!

ទីសំចតរបស់អត្តពលិកគឺជាជំហានដ៏សំខាន់នៅក្នុងការអះអាងថា ការលេងកីឡារបស់អ្នកនិងគូប្រកួតប្រជែងរបស់អ្នកស្ថិតនៅកម្រិតស្មើគ្នា។

- មានតែអត្តពលិកម្នាក់ឯងគត់ ជាអ្នកទទួលខុសត្រូវចំពោះទីកន្លែងសំចតរបស់ខ្លួន។
- អ្នកមិនអាចបន្ទោស អ្នកតំណាង ឬភ្នាក់ងាររបស់អ្នក សម្រាប់ការកែតម្រូវកន្លែងទីសំចតរបស់អ្នកឡើយ។
- ប្រសិនបើអ្នកស្ថិតនៅក្នុងបញ្ជីធ្វើតេស្តន៍ (RTP) អ្នកត្រូវតែផ្តល់កន្លែងទីសំចត រៀងរាល់ ៣ខែម្តង ដុច្នេះអ្នកអាចត្រូវបានកំណត់ទីតាំងសម្រាប់ការធ្វើតេស្ត។
- ប្រសិនបើឈ្មោះអ្នកបានបញ្ចូលទៅក្នុងបញ្ជីធ្វើតេស្តន៍(RTP)ចាំបាច់អ្នកត្រូវតែ បំពេញពត៌មានកន្លែងទីសំចតឱ្យបានត្រឹមត្រូវ។ សហព័ន្ធអន្តរជាតិ(IF) ឬអង្គការជាតិប្រឆាំងការប្រើប្រាស់ដូពីងរបស់អ្នក(NADO) នឹងផ្តល់ពត៌មានលម្អិតបន្ថែមបើសិនជាមានករណីចាំបាច់។
- ពត៌មានកន្លែងទីសំចត គឺជាធាតុមួយដ៏សំខាន់ នៅក្នុងការគាំទ្រសិទ្ធិរបស់អ្នកចំពោះ ការលេងកីឡាដោយភាពស្អាតស្អំ។

ភាពខុសប្លែកគ្នារវាងព័ត៌មាន និងច្បាប់ប្រឆាំងសារធាតុដូពីង/ដូប៉ាំពិភពលោកគឺមានន័យថាច្បាប់បានបង្ហាញពីលក្ខណៈនៃការប្រើប្រាស់ជាសកល។ រីឯព័ត៌មានវិញគឺអាចផ្លាស់ប្តូរបានគ្រប់ពេលវេលាទៅតាមព្រឹត្តិការណ៍។ អត្តពលិកត្រូវតែស្វែងរកមើលព័ត៌មាននៅក្នុងសហពន្ធ័អន្តរជាតិរបស់ខ្លួន អង្គការជាតិឬសហពន្ធ័ជាតិប្រឆាំងដូពីង/ដូប៉ាំដែលបានបញ្ចូលព័ត៌មានថ្មីៗនៅក្នុងនោះ។


WADA

wada-ama.org • info@wada-ama.org
facebook.com/wada-ama • twitter.com/wada_ama

Headquarters: 800 Place Victoria, Suite 1700, P.O. Box 120, Montreal, QC, H4Z 1B7, Canad • Tel.: +1.514.904.9232 • Tel.: +1.514.904.8650

Africa: Protea Assurance Building, 8th Floor, Greenmarket Square, Cape Town, 8001 South Africa • Tel.: +27.21.483.9791

Asia/Oceania: C/O Japan Institute of Sports Sciences, 3-15-1 Nishigaoka, Kita-Ku, Tokyo, 115-0056, Japan • Tel.: +81.3.5963.4321 • Tel.: +81.3.5963.4320

Europe: Maison du Sport International, Avenue de Rhodanie 54, 1007 Lausanne, Switzerland • Tel.: +41.21.343.43.40 • Fax.: +41.21.343.43.41

Latin America: World Trade Center Montevideo, Tower II, Unit 712, Calle Luis A De Herrea 1248, Montevideo, Uruguay • Tel.: +598.2.623.5206 • Fax.: +598.2.623.5207


ព័ត៌មានបន្ថែម: wada-ama.org

At-a-Glance

# ទីកន្លែងសំចត របស់អត្តពលិក



WORLD ANTI-DOPING AGENCY
play true

អត្តពលិកជាអ្នកការទូត និងជាជនគំរូបង្ហាញទៅពិភពលោកទាំងមូល។ ពួកគេមានការទទួលខុសត្រូវសំខាន់ក្នុងការ ការពារពីសុចរឹតភាពនៃកីឡារបស់ខ្លួន។ មានន័យថាវាជាផ្នែកមួយនៃភាតព្វកិច្ចរបស់អត្តពលិកដែលត្រូវតែផ្តល់ព័ត៌មានលម្អិតពីទីកន្លែងសំចតឬស្នាក់នៅរបស់ខ្លួនដើម្បីឲ្យអាជ្ញាធរប្រឆាំងការប្រើប្រាស់សារធាតុដូពីង/ដូប៉ា មានភាពងាយស្រួលក្នុងការវាយតម្លៃថាអត្តពលិកទាំងអស់ពួកគេលេងដោយសមត្ថភាពពិតៗ។

## ហេតុអ្វីត្រូវផ្តល់ព័ត៌មានពីទីកន្លែងសំចត ឬស្នាក់នៅរបស់ពួកគេ?

ការផ្តល់ពត៌មានពីទីកន្លែងសំចតគឺមានគោលបំណងដើម្បីការពារសិទ្ធិស្របច្បាប់របស់អត្តពលិកក្នុងការលេងកីឡាដោយភាពស្មោះត្រង់និងស្អាតស្អំ។ ពត៌មានពីទីសំចតបានផ្តល់នូវលក្ខណងាយស្រួលដល់អង្គការប្រឆាំងការប្រើប្រាស់សារធាតុដូពីង/ដូប៉ាក្នុងការតាមដានអត្តពលិកណាដែលលួចបន្លំប្រើប្រាស់សារធាតុហាមឃាត់។

> អត្តពលិកត្រូវតែយល់ដឹងពីកម្មវិធីប្រឆាំងការប្រើប្រាស់សារធាតុដូពីង/ដូប៉ា គឺវាមានសារៈសំខាន់ណាស់ដើម្បីធានាពីសុវត្ថិភាពនិងប្រសិទ្ធិភាពចំពោះវិស័យកីឡារបស់ខ្លួន។

## តើអ្នកណាខ្លះដែលត្រូវបានរួមបញ្ចូល ?

មានអត្តពលិកតិចតួចណាស់ដែលបានចុះឈ្មោះក្នុងបញ្ជីនៃការធ្វើតេស្ត (RTP) និងបានផ្តល់ទីកន្លែងពិតជាក់លាក់អំពីព័ត៌មានទីសំចតបច្ចុប្បន្នរបស់ខ្លួន។

> សហព័ន្ធអន្តរជាតិ និងអង្គការជាតិប្រឆាំងការប្រើប្រាស់ដូពីង/ដូប៉ា គឺជាអ្នកទទួលខុសត្រូវក្នុងការសម្រេចចិត្តឲ្យផ្តល់ពត៌មានពីទីកន្លែងសំចត ទោះបីជាអ្នកត្រូវបានទាមទារ ឬមិនបានទាមទារនៃទីសំចតក៏ដោយ ។

## តើខ្ញុំត្រូវការផ្តល់ពត៌មានអ្វីខ្លះ?

ប្រសិនបើអ្នកត្រូវបានណែនាំឲ្យផ្តល់ពត៌មានពីទីកន្លែងសំចតដោយអង្គការប្រឆាំងដូពីង/ដូប៉ា ADO ។ អ្នកត្រូវបានទាមទារឱ្យផ្តល់ពត៌មានមួយចំនួនដូចជា៖

- អាស័យដ្ឋានលំនៅដ្ឋាន
- ពត៌មាន និងទីកន្លែងហ្វឹកហាត់
- តារាងពេលវេលាប្រកួត
- សកម្មភាពផ្ទាល់ខ្លួន ជាទៀងទាត់ដូចជា ទីកន្លែងធ្វើការ ឬសាលារៀន
- អត្តពលិកទាំងនោះត្រូវបានរួមបញ្ចូលនូវការចុះឈ្មោះធ្វើតេស្តពេញលេញ RTP ដោយបានផ្តល់ការធ្វើតេស្ត ម្តងមានរយពេល៦០នាទី ក្នុងមួយថ្ងៃផងដែរ។

> នៅចងចាំបានទេថាអត្តពលិកទាំងអស់នៅតែអាចធ្វើតេស្តបាននៅគ្រប់ពេលវេលានិងគ្រប់ទីកន្លែងទាំងអស់។ ទោះបីជាអត្តពលិកដែលមានឈ្មោះនៅក្នុងបញ្ជីធ្វើតេស្ត (RTP) បើសិនជាពួកគេខកខានមិនបានធ្វើតេស្តនៅកំឡុងពេលដែលបានប្រកាស់ឲ្យមកធ្វើក្នុងរយពេកល ៦០ នាទីនោះអាចត្រូវបានធ្វើរបាយការណ៍។

មានហេតុការណ៍មួយចំនួនដែលត្រូវតែធ្វើការកែតម្រូវភ្លាមៗ

## អំពីព័ត៌មាននៃទីកន្លែងសំចតរបស់អត្តពលិក



- អ្នកអាចមានភាពងាយស្រួលក្នុងការកែតម្រូវនូវពត៌មានលម្អិតផ្សេងៗអំពីទីកន្លែងសំចតរបស់អ្នកដោយគ្រាន់តែផ្ញើសារទៅកាន់អង្គការដែលពាក់ព័ន្ធនានា (ADO) ឬការប្រើប្រាស់កម្មវិធីទូរស័ព្ទរបស់ WADAដើម្បីធ្វើការកែតម្រូវ។
- វាអាចនឹងមានផលវិបាកច្រើនប្រសិនបើអ្នកអវត្តមានដោយគ្មានមូលហេតុត្រឹមត្រូវ។ ប្រសិនបើអ្នកមិនបានមកទីតាំងដែលកំណត់សម្រាប់ការធ្វើតេស្ត អ្នកគួរតែពន្យល់ពីមូលហេតុ។
- អ្នកអាចជ្រើសរើសរកភ្នាក់ងារ ឬអ្នកតំណាងផ្សេងទៀតបានដើម្បីស្នើរកកន្លែងទីសំចតរបស់អ្នក ប៉ុន្តែអ្នក ត្រូវតែដឹងថាអ្នកគឺជាអ្នកទទួលខុសត្រូវចុងក្រោយសម្រាប់ពត៌មានទាំងនោះ។
- ប្រសិនបើអ្នកជាផ្នែកមួយនៃក្រុមនោះ ការផ្តល់ពត៌មានពីទីកន្លែងសំចត គ្រូបង្វឹក ឬមន្ត្រីតំណាងឲ្យក្រុម អាចស្នើសុំដាក់ឯកសារប្រមូលផ្តុំក្រុមរបស់អ្នកបាន។

## ការកែតម្រូវទីកន្លែងសំចត គឺមានភាពងាយស្រួល ជាមួយ ADAMS

ADAMS

ប្រព័ន្ធរដ្ឋបាល និងការគ្រប់គ្រងការប្រឆាំងដូពីងរបស់ WADA (ADAMS) គឺជាបណ្តាញមួយដែលអត្តពលិកអាចធ្វើការកែតម្រូវពត៌មានទីសំចតរបស់ពួកគេគ្រប់ទីកន្លែង និងគ្រប់ពេលវេលា រួមមានការផ្ញើសារ ទៅកាន់ ADAMS គឺអាចប្រើប្រាស់ជាភាសាអង់គ្លេស បារាំង អេស្ប៉ាញ អារ៉ាប់ ហូឡង់ ហ្វាំងឡង់ អាឡឺម៉ង់ អ៊ីតាលី ជប៉ុន និងរុស្ស៊ី។

ADAMS ត្រូវបានប្រើប្រាស់ដោយឥតគិតថ្លៃ និងមានភាពងាយស្រួលដល់អត្តពលិកគ្រប់រូបក្នុងការប្រើប្រាស់វា។ ហើយដំណើរការត្រួតពិនិត្យរបស់វាត្រូវបានធានានូវសុវត្ថិភាពពត៌មានផ្ទាល់ខ្លួនរបស់អ្នក។ ប្រសិនបើពួកគេមានគំរោងប្រើប្រាស់ ADAMS ទៅអនាគត់នោះ ពួកគេត្រូវតែស្នើសុំទៅអង្គការប្រឆាំងការប្រើប្រាស់សារធាតុដូពីង/ដូប៉ា ដែលជាប់ពាក់ព័ន្ធដើម្បីប្រើប្រាស់វា។

ពត៌មានបន្ថែម: wada-ama.org